**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤៨១
ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥

**សាលដីកា**

លេខៈ២១០
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក .............ជាចៅក្រមរបាយការណ៍
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .............

**តំណាងមហាអយ្យការ**

-ឯកឧត្តម .............ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១០៨(ឃ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤១៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ

ដើមចោទឈ្មោះកបយ(ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅផ្ទះលេខ១៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ចុងចម្លើយឈ្មោះគគជ(ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ២៥ ផ្លូវ៣៦៧ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ ក្រុងភ្នំពេញ។

- ចុងចម្លើយឈ្មោះសសខ និង ឈ្មោះចហ.

**<u>កម្មវត្ថុបណ្តឹងៈ</u>**ប្តឹងមោឃភាពកិច្ចសន្យាលក់-ទិញ

បានឃើញបណ្តឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះគគជប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៨(ឃ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៨១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៧-០១-២០០២ របស់ដើមចោទឈ្មោះកបយបានប្ដឹងសុំមោឃភាពកិច្ចសន្យាលក់ទិញផ្ទះ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០៤-១០-២០០១ ដោយហេតុ ថា : កាលពីថ្ងៃទី០៤-១០-២០០១ ខ្លួនបានខ្ចីប្រាក់ឈ្មោះចហ ចំនួន៩០០០ដុល្លាអាមេរិក ដោយឱ្យការប្រាក់ក្នុង១ខែ ៣៦០ដុល្លាអាមេរិក ។ នៅពេលខ្ចីប្រាក់នេះ ឈ្មោះចហ បានប្រើល្បិចលួងលោមឱ្យខ្លួនធ្វើកិច្ចសន្យាលក់ផ្ទះ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះដើម្បីប្រាក់បំណុលរបស់គាត់ ។ នៅខែ១២ និងខែ០១ ឆ្នាំ២០០២ នេះ ខ្លួនពុំបានបង់ការប្រាក់ឱ្យគាត់តាមកាលកំណត់ ស្រាប់តែឈ្មោះចហ នេះបានយកកំលាំងទាយានមកបណ្ដេញខ្លួនឱ្យរុះរើផាវាន់ចុះចេញពីផ្ទះ របស់ខ្លួន ។ ខ្លួនសុំរំលាយកិច្ចសន្យាលក់ទិញ និងលិខិតផ្ទេរសិទ្ធិ និងសុំឱ្យឈ្មោះថៅហ្វឹក ដឹកកំលាំងដែលមកដេកនៅផ្ទះរបស់ខ្លួនចេញ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ០២(ឱ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៤-១២-២០០២ របស់ឈ្មោះកបយភេទស្រី អាយុ៥៣ឆ្នាំ មានទីលំនៅក្រុមទី៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ប្ដឹងសុំហាមឃាត់ឈ្មោះថៅហ្វឹក មិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយទាន ដល់អ្នកដទៃជាបណ្ដោះអាសន្ននូវផ្ទះលេខ៥៨ ក្រុមទី៩ ផ្លូវលេខ៣៦៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ទណ្ឌមានជ័យ ក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះចហ ភេទប្រុស មិនឱ្យលក់-ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយទានទៅអ្នកដទៃជាបណ្ដោះអាសន្ន នូវផ្ទះលេខ៥៨ ផ្លូវលេខ៣៦៩ ក្រុមទី៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ទណ្ឌមានជ័យ ក្រុងភ្នំពេញ រង់ចាំតុលាការសម្រេចដល់រឿងអង្គ សេចក្ដី ។

៣-បង្គាប់ឱ្យឈ្មោះកបយបង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីអាន់ហិបប្រាក់២០០៛ សរុប២០០០៛ ប្រាក់នេះបានកាត់យកពី ប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-ដីការនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្ដឹងទាស់ក៏ដោយ ។

៥-បើគូភាគីណា មិនសុខចិត្តនិងដីកានេះ មានសិទ្ធិប្ដឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃដែលបានទទួលដីកាសម្រេចនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥៥(ឱ) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះកបយចុះថ្ងៃទី១៧-០១-២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ នឹងគតិច្បាប់ ។

២-ទទួលស្គាល់កិច្ចសន្យាលក់ផ្ទះ ចុះថ្ងៃទី៤-១០-២០០១ ជាច្បាប់របស់គូភាគី ផ្អែកតាមមាត្រា៣ នៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅតិច្ចសន្យា ។

៣-ប្រគល់ផ្ទះនិងដីស្ថិតក្នុងក្រុមទី៩ ភូមិជ្រោយបាសាក់ មណ្ឌល២ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានប័ណ្ណស្នាក់នៅលេខ១៩១៦ ក្បាល២.២ ទំព័រ៦៣ ចុះថ្ងៃទី១៨-៦-១៩៩៩ ឱ្យឈ្មោះចបហ ឈ្មោះគគជនិងឈ្មោះសសខ គ្រប់គ្រង ជាកម្មសិទ្ធិតាមស្មារតី នៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៤-បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបន្ត្រាក់២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០៛ សរុប៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍បង្គាប់ឱ្យដើមចោទបង់ប្រាក់១%នៃប្រាក់ចំនួន៩០០០ដុល្លាអាមេរិក ។ ប្រាក់នេះសំរាប់បង់ចូលថវិការដ្ឋ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៥-សាលក្រមនេះជំនុំជំរះនិង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៦(ឧ)ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះកបយប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥៥(ឧ)ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០៨(យ) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះកបយចុះថ្ងៃទី២៩-០១-២០០៩ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ៥៥(ឧ) ចុះថ្ងៃទី៣១-១២-២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-មោឃៈកិច្ចសន្យាលក់ផ្ទះនិងលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី៨-១០-២០០១ ។

៤-បង្គាប់ឱ្យឈ្មោះគគជចៅហ្វាក សឿង ស៊ីខេង ប្រគល់ផ្ទះ និងដីស្ថិតនៅក្នុងក្រុមទី៩ ភូមិជ្រោយបាសាក់ មណ្ឌល២ ឃុំព្រែកប្រា ទណ្ឌមានជ័យ រាជធានីភ្នំពេញឱ្យទៅឈ្មោះកបយ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៨៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៦-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២១-១១-២០០៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-១០-២០០៥ ចំពោះមុខគូភាគី ។ បើកផ្លូវសោទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះគគជប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៨(យ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះចៅហ្វីក គួចគឹមជូ និងឈ្មោះសឿង ស៊ីវខេង ។

បានស្តាប់រយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍សម្រេចសេចក្តី មកនេះត្រឹមត្រូវហើយ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះគួច គឹមជួ នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់មិនយុត្តិធម៌ ។ ប្រាក់នេះជាថ្លៃទិញផ្ទះ៣៦០ដុល្លា ជាថ្លៃឈ្នួលផ្ទះ គាត់មិនដែលឱ្យថ្លៃឈ្នួលផ្ទះទេ ។ រឿងនេះជារឿងទិញផ្ទះ មិនមែនចងការទេ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់អ្នកស្រីគួច គឹមជួ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការរៀបចំ និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ថ្វីត្បិតតែគូភាគីបានធ្វើកិច្ចសន្យាលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ជាលាយលក្ខណ៍អក្សរ និងមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានលើ កិច្ចសន្យាទាំងនោះក៏ពិតមែន ប៉ុន្តែក៏មានភស្តុតាងជាលិខិតចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ ដែលមានខ្លឹមសារថា : សុំសងប្រាក់ដើមចំនួន ៩០០០ដុល្លា និងការប្រាក់ ហើយនៅពេលដាក់ពាក្យបណ្តឹងតបចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០២ ភាគីចុងចម្លើយបានទាមទារប្រាក់ជំពាក់ចំនួន៩០០០ដុល្លា មិនមែនទាមទារសិទ្ធិគ្រប់គ្រងដី និងផ្ទះនោះទេ ។

- យល់ឃើញថា ក្នុងរឿងនេះ កិច្ចសន្យារបស់គូភាគីមានអត្ថន័យមិនច្បាស់លាស់ឡើយ ព្រោះកិច្ចសន្យាខ្លះមានខ្លឹមសារថា ជាការលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះ ហើយក៏មានកិច្ច សន្យាខ្លះមានខ្លឹមសារថា ជាការខ្ចីប្រាក់ ដូចនេះតាមមាត្រា២៣ នៃគ្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ត្រូវបានបកស្រាយជាប្រយោជន៍ នៃភាគីកូនបំណុល ហើយម្យ៉ាងទៀត កិច្ចសន្យារវាងគូភាគី ធ្វើឡើងក្នុងសភាពដែលភាគីម្ខាងឆ្លៀតទាញយកប្រយោជន៍ ពីភាគីម្ខាងទៀត ហើយមានភាពខុសគ្នា មិនសមស្របរវាងតាវកាលិក និងតម្លៃតបដែលដើមចោទ មានសិទ្ធិសុំមោឃភាពតាមមាត្រា១១.១២ នៃគ្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួល ខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចទុកជាមោឃៈកិច្ចសន្យាលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ហើយមិនបានសម្រេចឱ្យដើមចោទបង្វិលប្រាក់ ចំនួន៩០០០ដុល្លាអាមេរិក ទៅចុងចម្លើយ ដោយសំអាងថា ចុងចម្លើយមិនទាមទារប្រាក់នោះ ជាការខុសឆ្គងនឹងមាត្រា២១ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាហើយ ។

- យល់ឃើញថា តុលាការកំពូល បានជូនដំណឹងឱ្យដើមចោទតាមនីតិវិធីរួចហើយ ដើមចោទពុំបានចូលរួមនាសវនាការនេះទេ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៨(យ)ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះខុសខ្លះ គប្បីបង្វិលឱ្យជំនុំជំរះឡើងវិញនូវចំណុចខ្វះចន្លោះ ។

**ហេតុដូចនេះ**

**ឧនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់អ្នកស្រីគគជទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែគតិច្បាប់ត្រូវខ្វះខុសខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១០៨(យ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤៨១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះលើចំណុចប្រាក់ដើម ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីគួចគឹមដូ បានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺ

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ ។